# សុន្ទរកថាស្វាគមន៍

## ដោយ ឯកឧត្តម អង្គ វង្ស វឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ថ្លែងក្នុងពិធី "ប្រកាសការអនុវត្តក្រមរដ្ឋប្បវេណី"

**ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**

**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី**

**ជាតំណាងដ៏ខ្ពង់ខ្ពស់**

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

វិមានសន្តិភាព, រាជធានីភ្នំពេញ, ព្រឹកថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

*

សូមគោរព **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ អង្គទូត និងដៃគូសហប្រតិបត្តិការ ទាំងអស់...!

ថ្ងៃនេះ ក្រសួងយុត្តិធម៌ និងរូបខ្ញុំផ្ទាល់ មានកិត្តិយសខ្ពង់ខ្ពស់ណាស់ ដោយមានការអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធី **"ប្រកាសការអនុវត្តក្រមរដ្ឋប្បវេណី"** ។

នៅក្នុងឱកាសដ៏មហោឡារិកនេះ ក្រសួងយុត្តិធម៌មានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយក្រៃលែង សូមគោរពបង្ហាញជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គពិធីទាំងមូល អំពី **"ការប្រកាសការអនុវត្ត នូវច្បាប់ចំនួន ០៤ គឺៈ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង"** ដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងអស់រយៈពេល ជាង ១០ ឆ្នាំ របស់ក្រសួងយុត្តិធម៌ ដែលបានរៀបចំឡើងដោយមានជំនួយបច្ចេកទេសនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន ។

តាមពិត ក្រមរដ្ឋប្បវេណី ត្រូវបានអនុម័ត ដោយរដ្ឋសភានាថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំលើទី ៧ នីតិកាលទី ៣ ហើយត្រូវបានព្រឹទ្ធសភាយល់ព្រមតាមទម្រង់ និងគតិច្បាប់លើក្រមនេះទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី ២ ។ ពិតមែនតែ ក្រមរដ្ឋប្បវេណីនេះ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ប៉ុន្តែមិនទាន់អាចអនុវត្តបាននៅឡើយទេ គឺត្រូវរង់ចាំច្បាប់ដែលកំណត់កាលបរិច្ឆេទត្រូវអនុវត្តក្រមនេះ គឺច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដោយហេតុថាទំនាក់ទំនងរដ្ឋប្បវេណីនេះ មានភាពស្មុគ្រស្មាញ ទាំងការបកស្រាយ និងទាំងការអនុវត្ត ជាមួយនឹងបណ្តាច្បាប់មួយចំនួនដូចជា ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច. ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ភូមិបាល ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា ។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលកំណត់ការអនុវត្តក្រមរដ្ឋប្បវេណី ដែលត្រូវដាក់ឱ្យអនុវត្ត នៅថ្ងៃទី ២១ ធ្នូ ឆ្នាំ ២០១១ នេះ ត្រូវបានរៀបចំឡើង ដើម្បីសម្របសម្រួលជាមួយបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តចរមាននានា ឱ្យមានភាពស៊ីសង្វាក់នៅក្នុងការអនុវត្ត និងក្នុងគោលបំណងធានាស្ថិរភាពនៃទំនាក់ទំនងគតិយុត្ត ផ្នែករដ្ឋប្បវេណី និងធានាឱ្យមានការអនុវត្តឱ្យបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

ការចាប់ផ្តើមអនុវត្តនៃច្បាប់ទាំង ០៤ នេះ ជាសក្ខីភាពមួយនៃសមិទ្ធកម្មក្នុងការកសាងក្របខណ្ឌច្បាប់ ស្របតាមគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក៏ដូចជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋា-ភិបាលកម្ពុជា ចំពោះសហគមន៍អន្តរជាតិផងដែរ ហើយក៏ជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយ នៃការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ក្នុងវិស័យរដ្ឋប្បវេណីដ៏រឹងមាំមួយ ដែលនឹងជួយបំពេញបន្ថែមឱ្យនីតិរដ្ឋមាន ក្នុងវិស័យរដ្ឋប្បវេណីនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**
**ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីគោរព និងជាទីមេត្រី !**

ខ្ញុំសូមអនុញ្ញាតរំលឹកអំពីការងារកសាងក្រមនេះ ថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសកម្ពុជាដែលចង់បានប្រព័ន្ធច្បាប់រដ្ឋប្បវេណី ច្បាស់លាស់ និងពេញលេញ ដែលជាអត្ថបទច្បាប់ដ៏ចំបងនៃនីតិរដ្ឋ និងជាមធ្យោបាយដ៏សំខាន់របស់តុលាការរដ្ឋប្បវេណី ក្នុងការផ្តល់យុត្តិធម៌រដ្ឋប្បវេណី

នៅឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងយុត្តិធម៌ បានស្នើសុំសហប្រតិបត្តិការជប៉ុន ដើម្បីជួយរៀបចំជាក្រមក្នុងវិស័យរដ្ឋវេណី ដោយយកបញ្ញត្តិជាធរមានក្នុងវិស័យនេះ មកធ្វើការពិនិត្យកែសម្រួល និងបំពេញបន្ថែម ទៅតាមបរិបទ និងការវិវត្តនៃសង្គម ដោយរក្សាផងដែរ នូវនិរន្តភាពនៃស្ថាប័ន ស្របតាមប្រពៃណីច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ដោយ មើលឃើញ អំពីភាពចាំបាច់ និងសារៈសំខាន់នៃការអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាល អំពីក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធទាំងនេះ ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្ត លើកកំពស់ការយល់ ដឹងរបស់ប្រជាពលរដ្ឋ និងការពង្រឹងនីតិរដ្ឋ ក្រសួងយុត្តិធម៌ ដោយមានការជួយគាំទ្រពីសហប្រតិបត្តិការ ជប៉ុន បានរៀបចំកម្មវិធីផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីខ្លឹមសារនៃក្រមនេះ និងច្បាប់ពាក់ព័ន្ធ ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ ព្រមទាំងបានរៀបចំ និងបោះពុម្ពនូវសៀវភៅស្តីពីកំណត់ពន្យល់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង និងបានចែក ជូនយ៉ាងទូលំទូលាយ ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ស្ថាប័នពាក់ព័ន្ធ និងសាធារណៈជន។

ពិធីប្រកាស "**ការអនុវត្តក្រមរដ្ឋប្បវេណី**" ដែលប្រព្រឹត្តទៅនៅថ្ងៃនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានរបស់តំណាងជាន់ខ្ពស់ នៃស្ថាប័នរដ្ឋាភិបាល អង្គការនីតិបញ្ញត្តិ អង្គការតុលាការ តំណាងគណៈមេធាវី តំណាងស្ថានទូត និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ សាកលវិទ្យាល័យច្បាប់ និងនិសិត្ស ប្រមាណជាង ៧០០ នាក់ មានគោលបំណងធ្វើការផ្សព្វផ្សាយ និងក្រកាសការអនុវត្តជាផ្លូវការនូវ "**ក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធ**" ក្រមនេះក្នុងកម្រិតជាតិ ក៏ដូចជាការអបអរសាទរចំពោះសមិទ្ធផលដ៏ធំនៃ នយោបាយទំនើបកម្មក្របខណ្ឌច្បាប់ ដែលជាមូលដ្ឋាននៃនីតិរដ្ឋ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងយុត្តិធម៌ជាសេនាធិការក្នុងវិស័យនេះ ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុងឧត្តមនេះ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចំពោះការយកចិត្តទុកដាក់ដឹកនាំ និងតំរង់ទិសដល់យើងខ្ញុំ ដែលជានិច្ចកាល **សម្តេច** តែងបានបានផ្តល់នូវការគាំទ្រ និងលទ្ធភាពគ្រប់បែបយ៉ាង ជួយដល់ក្រសួងយុត្តិធម៌ ដើម្បីសំរេចបាននូវ

ជោគជ័យរបស់ខ្លួនជាបន្តបន្ទាប់ នៅក្នុងការកសាងក្របខណ្ឌច្បាប់ សំដៅពង្រឹងប្រព័ន្ធយុត្តិធម៌ ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃសេវាយុត្តិធម៌ ជូនដល់ប្រជាពលរដ្ឋ និងលើកកំពស់នីតិរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជាយើង ។

ដោយមើលឃើញអំពីភាពចាំបាច់ និងសារៈសំខាន់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត លើកកំពស់ការ យល់ដឹងរបស់ប្រជាពលរដ្ឋ និងការពង្រឹងនីតិរដ្ឋ ក្រសួងយុត្តិធម៌ ដោយមានការជួយគាំទ្រពីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន បានរៀបចំពិសិដ្ឋីទជាតិផ្សព្វផ្សាយ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ដែលកំពុងប្រារព្ធឡើងនាពេលនេះ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។

លើសពីនេះទៀត ជាការបន្ថែមទៅលើសមិទ្ធផលដែលបានទទួលកន្លងមក ក្រសួងយុត្តិធម៌សូមប្តេជ្ញាចិត្តថានឹងពង្រឹង និងពង្រីកការងារអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីក្រម និងច្បាប់ទាំងនេះ ឱ្យបានកាន់តែច្រើន មានទ្រង់ទ្រាយធំទូលាយ រហូតដល់ប្រជាពលរដ្ឋមូលដ្ឋាន ព្រោះថា ក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធទាំងនេះ មានទំនាក់ទំនងដោយផ្ទាល់ដល់សកម្មភាព និងជីវភាពប្រចាំថ្ងៃរបស់ជនគ្រប់រូប ព្រមទាំងជម្រុញការរៀបចំ និងការអនុម័តច្បាប់ និងបទប្បញ្ញត្តិដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់ទាំងនេះ ដើម្បីធានាភាពរលូន និងប្រសិទ្ធិភាពនៃការអនុវត្ត ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានចំណាយពេលវេលាដ៏មានតំលៃ និងមមារញឹកបំផុតក្នុងភារកិច្ច អញ្ជើញជាអធិបតី ផ្តល់កិត្តិយសដ៏ឧត្តុងឧត្តមដល់ពិធី ប្រកាសការអនុវត្តក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងញ៉ាំងឱ្យពិធីនេះមានភាពមហោឡារិក និងអធិកអធមយ៉ាងក្រៃលែង ។ ហើយជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយស ជាតិ អន្តរជាតិ និងសមាជិក សមាជិកានៃអង្គពិធីទាំងមូល ដែលបានអញ្ជើញចូលរួមយ៉ាងច្រើនកុះករ ដើម្បីគាំទ្រដល់ពិធីនេះ ។

**សូមអរគុណ !**